# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ៣៤៦ គ.ជ.ប

# គោលការណ៍
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

### ១. គោលបំណង

កម្មវិធីស្មើភាព ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ នៅតាមមណ្ឌលបោះឆ្នោតនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយដែលបានទទួលស្គាល់ជាផ្លូវការដោយ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) មានឱកាសផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ដែលកម្មវិធីនេះត្រូវចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ (វិទ្យុជាតិកម្ពុជា និងទូរទស្សន៍ជាតិកម្ពុជា)។

### ២. ការផ្សព្វផ្សាយកម្មវិធីស្មើភាព

កម្មវិធីស្មើភាព ដែលត្រូវចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ មានដូចខាងក្រោម៖

២.១ កម្មវិធីតុមូល ដែលតម្រូវឱ្យគណបក្សនយោបាយឆ្លើយសំណួរទៅតាមប្រធានបទដែលកំណត់ដោយ គ.ជ.ប។

២.២ កម្មវិធីស្ប៉តគោលនយោបាយ ដែលផលិតដោយសាមីគណបក្សនយោបាយ។

២.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយលើព្រឹត្តិបត្រគោលនយោបាយគណបក្ស ដែលបោះពុម្ពផ្សាយដោយ គ.ជ.ប។

ការរៀបចំកម្មវិធីទាំង ៣ (បី) ខាងលើនេះ ត្រូវស្ថិតក្រោមការរៀបចំ ចាត់ចែង និងពិនិត្យដោយគណៈកម្មការសម្របសម្រួល។

## ៣. ការអនុវត្តគោលការណ៍

ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ ត្រូវអនុវត្តតាមគោលការណ៍ស្មើភាព ដោយគណបក្សនយោបាយនីមួយៗទទួលបានម៉ោងផ្សាយតាមវិទ្យុជាតិកម្ពុជា និងទូរទស្សន៍ជាតិកម្ពុជាស្មើៗគ្នា ហើយរយៈពេលនេះនឹងត្រូវចាក់ផ្សាយឡើងវិញក្នុងថ្ងៃដដែល។

## ៤. ការទទួលខុសត្រូវរបស់គណបក្សនយោបាយ

គណបក្សនយោបាយ ត្រូវគោរពតាមការរៀបចំ និងចាត់ចែងដោយគណៈកម្មការសម្រប-សម្រួល ដែលរៀបចំការចាប់ឆ្នោតយកលំដាប់លេខរៀងមុនក្រោយសម្រាប់ការថត ទីកន្លែងអង្គុយ ម៉ោងផ្សាយ លេខរៀងផ្សាយ និងគោរពតាមបទបញ្ជាគុមូល សម្រាប់ការថតកម្មវិធី។

គណបក្សនយោបាយដែលចូលរួមក្នុងកម្មវិធីស្មើភាព ត្រូវតែគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត និងគោរពតាមគោលការណ៍នេះ។

## ៥. ការទទួលខុសត្រូវខ្លឹមសារផ្សព្វផ្សាយ

គ.ជ.ប ជាអ្នកទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយកម្មវិធីស្មើភាព ដែលរៀបចំឡើងដោយ គ.ជ.ប។

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ